# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ៤១៥
ចុះថ្ងៃទី០៩-៣-២០២០
សាលដីកា
លេខ៖ ១២៧ ក្រ II «ស»
ចុះថ្ងៃទី ០៥-១០-២០២០

បង្កើតតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

កញ្ញា [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤១៥ ចុះថ្ងៃទី០៩-៣-២០២០ លើជនជាប់ចោទ៖

១-ឈ្មោះ [redacted]សម្បត្តិ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត ភូមិទួលគោក សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និងទីលំ[redacted]ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣០ ចុះថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០១៩។

-មានលោក [redacted] វុន និង លោក [redacted] ឬរៈភុន ជាមេធាវីការពារសិទ្ធិ។

២-ឈ្មោះ [redacted] បំណាង ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបររត់តាក់ស៊ី ទីកន្លែងកំណើតភូមិស្វាយ ឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត និងទីលំនៅបច្ចុប្បន្ន ភូមិត្រពាំងរពៅ ឃុំព្រៃកគ្នោក ស្រុកទឹកឈូ ខេត្តកំពត ឪពុកឈ្មោះ [redacted] សុខុន ម្តាយឈ្មោះ [redacted] ឈិន ប្រពន្ធឈ្មោះ [redacted] កប មានកូនចំនួន ០៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣២ ចុះថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០១៩ ។





Scanned with CamScanner

**ជាប់ចោទពីបទ៖** ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត នៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**<u>រឿងហេតុមានដូចតទៅ÷</u>**

តាមអង្គហេតុដែលបានចោទប្រកាន់ឃើញថា កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ០០ នាទី កម្លាំងសមត្ថកិច្ចបានបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ០១ករណី នៅចំណុចភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ដោយឃាត់ខ្លួនបានជនសង្ស័យ ចំនួន ០២នាក់ រួមមានឈ្មោះ [redacted]សម្បត្តិ ភេទប្រុស អាយុ ២៨ឆ្នាំ និងឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ ដោយបានដកហូតថ្នាំញៀន ចំនួន ០៣កញ្ចប់ ទម្ងន់ ១០៥,៨៨ក្រាម ជញ្ជីងថ្លឹងអេឡិចត្រូនិចចំនួន ០១គ្រឿង រថយន្តសាំងយ៉ុង ០១គ្រឿង និងថង់ប្លាស្ទិចមួយចំនួន។ បន្ទាប់មកសមត្ថកិច្ចបានបញ្ជូនជនសង្ស័យទាំងពីរនាក់ និងវត្ថុតាងមកអយ្យការដើម្បីចាត់ការតាមច្បាប់។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ៥ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ÷**

១.ផ្តន្ទាទោស ជនជាប់ចោទ៖

១.ឈ្មោះ[redacted]សម្បត្តិ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កំណត់រយៈពេលចំនួន ១៣ (ដប់បី)ឆ្នាំ គិតពីថ្ងៃឃុំខ្លួន។

២. ឈ្មោះ[redacted] សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ កំណត់រយៈពេលចំនួន ១០ (ដប់)ឆ្នាំ គិតពីថ្ងៃឃុំខ្លួន។

ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.វត្ថុតាងមាន:

-គ្រឿងញៀនប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន ០៣កញ្ចប់តូច និង ០២កញ្ចប់ធំ ទម្ងន់ ១០៥,៨៨ក្រាម (ក្នុងកញ្ចប់បិទជិត), ជញ្ជីងថ្លឹងគ្រឿងញៀន ០១គ្រឿង និងថង់ច្រកគ្រឿងញៀនមួយចំនួន ត្រូវរឹបអូស និងបំផ្លាញចោល យោងតាមបញ្ញត្តិមាត្រា ៨៤ និង មាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។



Scanned with CamScanner

-បានឃើញ សេចក្ដីសុំប្ដឹងតវ៉ាលេខ ២៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ ។

-បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង**

-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ (វត្តមាន)

-លោក [redacted] សុរ:គុន និងលោក ហែមរុន ជាមេធាវីការពារសិទ្ធិ (វត្តមាន) ។

-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ឆ្លើយថា៖ ថ្នាំញៀន រួមទាំងជញ្ជីងថ្លឹងគ្រឿងញៀនជារបស់ឈ្មោះ [redacted] សំណាង។ ខ្លួនជិះឡានរបស់ សំណាង ម៉ាកស៊ាំយ៉ុងជាមួយគ្នា ហើយប៉ូលីសធ្វើការឃាត់ខ្លួននៅបូកគោ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន ដោយថ្នាំញៀននោះបានមកពីឈ្មោះ សំណាង។ ខ្លួនបានស្គាល់ សំណាង មួយរយៈពេលហើយ ដោយគាត់ត្រូវជាមិត្តរបស់បងប្រុសខ្លួន។ ខ្លួនមានមុខរបរធ្វើការនៅអង្គការប្រាក់កម្ចីមួយ។ ខ្លួនសូមបដិសេធចំពោះចម្លើយទាំងអស់ដោយតុលាការថ្នាក់ក្រោម គេវាយបង្ខំអោយខ្លួនផ្ដល់ចម្លើយ។

**<u>តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន៖</u>**

ជនជាប់ចោទបានបដិសេធថា មិនមែនជាថ្នាំរបស់គាត់ទេ តែនៅតុលាការថ្នាក់ក្រោមគាត់បានទទួលស្គាល់ចំពោះគ្រឿងញៀននេះ។ បរិមាណធាតុសុទ្ធចំពោះសារធាតុញៀនគឺមានចំនួន ៨៩ក្រាម។ ការផ្ដន្ទាទោសរបស់សាលាដំបូង គឺស្ថិតនៅក្នុងអប្បបរមាហើយ។ ដូច្នេះ ស្នើសុំអោយក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រមទុកជាបានការដដែល។

**<u>មេធាវីការពារសិទ្ធិជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន៖</u>**

កូនក្ដីរបស់ខ្លួនបានបដិសេធចម្លើយនៅក្នុងឯកសារផ្សេងៗ។ កូនក្ដីរបស់ខ្លួនពុំធ្លាប់ផ្ដន្ទាទោសពីមុននោះឡើយ។ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះកែប្រែពីបទប្រើប្រាស់ និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកជាបទប្រើប្រាស់គ្រឿងញៀនវិញ តែបើក្រុមប្រឹក្សាជំនុំជម្រះរកឃើញថា មានការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណាអំពីស្ថានសម្រាលទោសដល់កូនក្ដីខ្លួនផង។

**<u>សំណូមពររបស់ជនជាប់ចោទ៖</u>**

-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ សំណូមពរ ស្នើសុំបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ ។

-ក្រោយពីបានស្ដាប់សំណូមពររបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។



Scanned with CamScanner

## សាលាឧទ្ធរណ៍ភ្នំពេញ

### យល់ឃើញថា៖

១/បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ២៦៧ ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ គ្រប់ចំណុច សេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៨៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៨២ នៃច្បាប់ស្តីពីកិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ក្រុមប្រឹក្សាជំនុំជម្រះទទួលជំនុំជម្រះបាន។

២/តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល ឃើញថា៖ កាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ០០ នាទី នៅចំណុចភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត សមត្ថកិច្ចបានធ្វើការឃាត់ខ្លួន ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សំណាង ដោយបានដកហូតនូវថ្នាំញៀនដែលប្រភេទមេតំហ្វេតាមីនទម្ងន់សរុប ១០៥,៨៨ក្រាម ដែលមានបរិមាណធាតុសុទ្ធទម្ងន់ ៨៩,១២១ក្រាម ហើយសមត្ថកិច្ចបានធ្វើតេស្តស្វែងរកសារធាតុញៀន លើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ លទ្ធផលវិជ្ជមាន ប្រាកដមែន ដែលជាទម្រង់មួយនៃអំពើមានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ពីបទ ជួញដូរ និងប្រើប្រាស់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីគ្រឿងញៀន ដូចមាននិន្នន័យសារក្នុងផ្នែកសំអាងហេតុ នៃសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង បញ្ជាក់ស្រាប់ ហើយក្រុមប្រឹក្សាជំនុំជម្រះ បានឯកភាព នឹងសំអាងហេតុនេះដោយមិនចាំបាច់លើកយកសំអាងហេតុដដែលនោះមកបញ្ជាក់ជាថ្មីទៀតទេ។

៣/តំណាងមហាអយ្យការបានធ្វើការសន្និដ្ឋានថា៖ ជនជាប់ចោទបានបដិសេធថា មិនមែនជាថ្នាំរបស់គាត់ទេ តែនៅតុលាការថ្នាក់ក្រោម គាត់បានទទួលស្គាល់ចំពោះគ្រឿងញៀននេះ។ បរិមាណធាតុសុទ្ធចំពោះសារធាតុញៀនគឺមានចំនួន ៨៩ក្រាម។ ការផ្តន្ទាទោសរបស់សាលាដំបូង គឺស្ថិតនៅក្នុងអប្បបរមាហើយ។ ដូច្នេះ ស្នើសុំអោយក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រមទុកជាបានការដដែល។

ឃើញថា សេចក្តីសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៤/ការដែលជនជាប់ចោទបដិសេធថា មិនមែនជាគ្រឿងញៀនរបស់ខ្លួននោះ ឃើញថា មិនត្រឹមត្រូវទេ ព្រោះតាមកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យប្រឆាំងគ្រឿងញៀន គឺបានដលហូតម៉េត្រាំពណ៌សថ្លាទម្ងន់១០៥,៨៨ក្រាម ដែលជាគ្រឿងញៀនពីឈ្មោះ [redacted] សម្បត្តិ។ ម៉្យាងទៀត ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានឆ្លើយទទួលស្គាល់ គ្រប់ដំណាក់កាលនៃនីតិវិធីថា ជាគ្រឿងញៀនរបស់ខ្លួន ។

៥/ការដែលជនជាប់ចោទក៏ដូចជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទស្នើសុំអោយក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសនោះ ឃើញថា មានលក្ខណៈត្រឹមត្រូវ ដែលគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចបន្ធូរបន្ថយទោស តាមកំណត់ច្បាប់ ដោយផ្អែកទៅលើបរិមាណធាតុសុទ្ធនៃគ្រឿងញៀនដែលបានដកហូតពីជនជាប់ចោទ ។



Scanned with CamScanner

៦/សាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពត សម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីក្រុមប្រឹក្សាជំនុំជម្រះតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១.១ផ្តន្ទាទោសជនជាប់ចោទ [redacted] សម្បត្តិ គប្បីកែប្រែតាមសំអាងហេតុខាងលើ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១/ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២/តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពត ទុកជាបានការ លើកលែងតែចំណុចទី១.១ ដែលផ្តន្ទាទោសឈ្មោះ [redacted] សម្បត្តិ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ១៣(ដប់បី)ឆ្នាំ ត្រូវបន្ថយមកត្រឹម ១១ (ដប់មួយ)ឆ្នាំ វិញ។ why?

-ចំណុចផ្សេងពីនេះរក្សាទុកដដែល ។

៣/បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤/សាលដីកានេះ ជំនុំជម្រះជាសាធារណៈថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ។

-បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted], [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]